ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សតាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៥១៧

ចុះថ្ងៃទី ១៥-០៦-២០១១

សាលដីកា

លេខ ៖ ៤៦ "ក្រ.III.ស"

ចុះថ្ងៃទី ២៨-០៦-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៥១៧ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១១ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត ហៅ ឌិត ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនិងរស់នៅ [redacted] ស្រុកកៀនស្វាយ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ទោសគ្មានពីមុន។

មានលោក [redacted] ទ្ធារិទ្ធ ជាមេធាវីការពារ។

ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចស្ទួនវិមានឯករាជ្យ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- ជនរងគ្រោះឈ្មោះ [redacted] ពន្លក ភេទប្រុស អាយុ ១៣ឆ្នាំ ជាតិខ្មែរ មុខរបរសិស្សថ្នាក់ទី ៨ នៃវិទ្យាល័យទួលប្រាសាទ សែន សុខ ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

## ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ២១ និង៣០នាទី ជនរងគ្រោះឈ្មោះ [redacted] ពន្លក បានដើរលេងកំសាន្តក្នុងពិធីបុណ្យអុំទូក ពេលធ្វើដំណើរមកដល់សួនវិមានឯករាជ្យ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជនរងគ្រោះបានឈរនិយាយទូរស័ព្ទ ពេលនោះជនល្មើសឈ្មោះ [redacted] បណ្ឌិត បានធាក់ និងឆក់ដណ្តើមទូរស័ព្ទរបស់ជនរងគ្រោះម៉ាក Metfone រួចរត់គេចខ្លួន តែត្រូវសមត្ថកិច្ចឃាត់ខ្លួនបាន។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៦ ក្រ១ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសឈ្មោះ [redacted] បណ្ឌិត ហៅ ឌិត ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៥ឆ្នាំ (ប្រាំឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចសួនវិមានឯករាជ្យ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១០ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២- ទុកសិទ្ធិឲ្យជនរងគ្រោះឈ្មោះ [redacted] ពន្លក ប្តឹងទាមទារតាមច្បាប់នៅពេលក្រោយ។

៣- សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៣៧៥ ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] បណ្ឌិត ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៦ ក្រ១ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះឈ្មោះ [redacted] ពន្លក បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មកនេះដើម្បីសុំឲ្យតុលាការបន្ធូរបន្ថយទោសខ្លួនផង។ ខ្លួនទើបប្រព្រឹត្តលើកទី ១ ខ្លួនសុំសារភាព ខ្លួនដើរទៅឃើញជនរងគ្រោះកាន់ទូរស័ព្ទកំពុងនិយាយ ខ្លួនចូលទៅឆក់យកទូរស័ព្ទ តែខ្លួនមិនបានវាយជនរងគ្រោះទេ។ ពេលខ្លួនឆក់ខ្លួនអត់បានធាក់ទេ ជនរងគ្រោះគាត់អង្គុយនិយាយទូរស័ព្ទ ខ្លួនក៏ឆក់នៅក្បែរវិមានឯករាជ្យ ខ្លួនទៅពីក្រោយឆក់តែម្តង។ ថ្ងៃកើតហេតុថ្ងៃបុណ្យអុំទូកទី ២ ខ្លួនឆក់មែន តែមិនបានទាត់ទេ គឺពេលនោះមានមនុស្សច្រើន។ សំណូមពរ សុំតុលាការសាលាឧទ្ធរណ៍មេត្តាបន្ធូរបន្ថយទោសឲ្យខ្លួនផង។

### សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត ដូចបទចោទប្រកាន់របស់អយ្យការសាលាដំបូង (ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត នៅសមត្ថកិច្ចនគបាល ស៊ីសង្វាក់ជាមួយនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ពន្លក ឃើញថា ជាបទល្មើសជាក់ស្ដែង ចាប់បានជនជាប់ចោទភ្លាមៗ)។ សាលក្រមរបស់សាលាដំបូងដែលបានសម្រេចមកនេះត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការដដែល។

### សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

កាលពីថ្ងៃទី ២១ ខែវិច្ឆិកាឆ្នាំ២០១០ កូនក្ដីខ្លួនបានធ្វើសកម្មភាពឆក់ទូរស័ព្ទរបស់ជនរងគ្រោះនៅវិមានឯករាជ្យ កូនក្ដីខ្លួនបានសារភាពតាំងពីដំបូង គាត់ប្ដឹងឧទ្ធរណ៍មកដើម្បីឲ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់រូបគាត់ គាត់ថា មិនបានធាក់ជនរងគ្រោះទេ តែចម្លើយរបស់ជនរងគ្រោះថា កូនក្ដីខ្លួនបានធាក់។ រាល់ចម្លើយមានបួនដំណាក់កាល ហើយកូនក្ដីខ្លួនបានសារភាពថា បានឆក់ តែមិនបានធាក់ទេ ហើយក៏មិនមានកោសល្យវិច័យបញ្ជាក់ដែរ សូមក្រុមប្រឹក្សាកែប្រែបទចោទ ពីមាត្រា ៣៥៧ ទៅមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១- បណ្ដឹងឧទ្ធរណ៍លេខ ៣៧៥ ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] បណ្ឌិត ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទសារភាពដោយបញ្ជាក់ច្បាស់លាស់ថា កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១០ ជាថ្ងៃបុណ្យអុំទូកទី ២ ខ្លួនពិតជាបានឆក់ទូរស័ព្ទដៃពីជនរងគ្រោះឈ្មោះ [redacted] ពន្លក ប្រាកដមែន រួចរត់គេចខ្លួន ភ្លាមតែត្រូវសមត្ថកិច្ចចាប់ខ្លួនបានភ្លាមៗដែរ។ ខ្លួនឆក់តែម្នាក់ឯង គ្មានបក្សពួកទេ។

៣- មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទ លួចដោយហិង្សា ប្រព្រឹត្តនៅចំណុចសួនវិមានឯករាជ្យ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១០ បទល្មើសមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៤៦ ក្រ១ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានសំអាងហេតុ និងសេចក្តីសម្រេចច្បាស់លាស់គ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៧៥ ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ អន បណ្ឌិត ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៦ ក្រ១ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 18 ខែ02 ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]